ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ.....០០៦........អ.ស.ហ.ស.ស.ម

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០០៤ អ.ស.ហ.ប្រក. ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមតម្រូវការចាំបាច់របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលមានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| - ឯកឧត្តម **ម៉ី វ៉ាន់** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) | ប្រធាន |
| - ឯកឧត្តម **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. និងជាអគ្គនាយកនៃនិយ័តករសន្តិសុខសង្គម | អនុប្រធាន |
| - ឯកឧត្តម **ស៊ូ សុជាតិ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា | អនុប្រធាន |
| - ឯកឧត្តម **សុខ ដារ៉ា** | អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច | អនុប្រធាន |
| - ឯកឧត្តម **ម៉ូ ចារិន** | អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម | អនុប្រធាន |
| - ឯកឧត្តម **ជូ វណ្ណៈ** | អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | អនុប្រធាន |
| - លោក **សោម ផៃ** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. | អនុប្រធាន |
| - លោកស្រី **ហោ សុវឌ្ឍនា** | អគ្គនាយករងនៃនិយ័តករធានារ៉ាប់រងកម្ពុជា | អនុប្រធាន |
| - ឯកឧត្តម **ចិន ភក្តី** | អគ្គនាយករងនៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| - ឯកឧត្តម **ឈី សាភល** | អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| - លោកស្រី **ផន ភេណ្ណារ័ត្ន** | អគ្គនាយករងនៃនិយ័តករសន្តិសុខសង្គម | សមាជិក |
| - លោកស្រី **នាន បូនី** | អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| - លោក **សូ សុភា** | ប្រធានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. | សមាជិក |
| - លោក **ខូច អៀហៃ** | ប្រធាននាយកដ្ឋាននៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| - លោក **ឃុន គីមលៀង** | ប្រធាននាយកដ្ឋាននៃនិយ័តករមូលបត្រកម្ពុជា | សមាជិក |
| - លោក **ឡេង សុខឡុង** | ប្រធាននាយកដ្ឋាននៃនិយ័តករសន្តិសុខសង្គម | សមាជិក |
| - លោក **លី ស៊ូភេន** | ប្រធាននាយកដ្ឋាននៃនិយ័តករសន្តិសុខសង្គម | សមាជិក |
| - លោក **ម៉ៅ ពៅ** | ប្រធាននាយកដ្ឋាននៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | សមាជិក |
| - លោក **ហាយ សុវណ្ណា** | មន្ត្រីដឹកនាំការងារនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច នៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| - លោក **រិន រដ្ឋា** | អនុប្រធាននាយកដ្ឋាននៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| - លោក **ឈាន សេរីវុធ** | អនុប្រធាននាយកដ្ឋាននៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| - លោកស្រី **ថោ សេដ្ឋចាន់លីដា** | អនុប្រធាននាយកដ្ឋាននៃនិយ័តករគណនេយ្យនិងសវនកម្ម | សមាជិក |
| - លោក **ព្រំ សេរីឧត្តម** | អនុប្រធាននាយកដ្ឋាននៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | សមាជិក |
| - លោក **ឌីវ ម៉ារ៉ាដែន** | អនុប្រធាននាយកដ្ឋាននៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | សមាជិក។ |

**ប្រការ២.-**

ក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- រៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- ស្រាវជ្រាវអំពីការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល, ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ, ការលើកកម្ពស់ការប្រើប្រាស់និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និងការជំរុញការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលរួមបញ្ចូលទាំងហិរញ្ញវត្ថុវិមជ្ឈការឬបច្ចេកវិទ្យាដែលកំពុងលេចឡើង ជាគុណប្រយោជន៍ដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុ
- សិក្សានិងវាយតម្លៃស្ថានភាព បទពិសោធ ឧត្តមានុវត្តន៍ និងនិន្នាការនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងបរិការណ៍កម្ពុជា តំបន់ និងសកល
- ដឹកនាំ សហការ សម្របសម្រួល និងរៀបចំកិច្ចប្រជុំនិង/ឬសិក្ខាសាលាពិគ្រោះយោបល់ជាមួយនឹងក្រសួង-ស្ថាប័នឬអង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីទាញយកបទពិសោធនិងប្រមូលធាតុចូលបន្ថែម តាមការចាំបាច់
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារ។

**ប្រការ៣.-**

ក្រុមការងាររៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានក្រុមការងារបច្ចេកទេសមួយជាសេនាធិការក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| - លោក **សូ សុភា** | ប្រធានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. | ប្រធាន |
| - លោក **ខូច អៀហៃ** | ប្រធាននាយកដ្ឋាននៃនិយ័តករធានារ៉ាប់រងកម្ពុជា | អនុប្រធាន |
| - លោក **ឃុន គីមលៀង** | ប្រធាននាយកដ្ឋាននៃនិយ័តករមូលបត្រកម្ពុជា | អនុប្រធាន |
| - លោក **ឡេង សុខឡុង** | ប្រធាននាយកដ្ឋាននៃនិយ័តករសន្តិសុខសង្គម | អនុប្រធាន |
| - លោក **លី ស៊ូគេន** | ប្រធាននាយកដ្ឋាននៃនិយ័តករសន្តិសុខសង្គម | អនុប្រធាន |
| - លោក **ម៉ៅ ពៅ** | ប្រធាននាយកដ្ឋាននៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | អនុប្រធាន |
| - លោក **ហាយ សុវណ្ណា** | មន្ត្រីដឹកនាំការងារនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច នៃនិយ័តករបរធនបាលកិច្ច | អនុប្រធាន |
| - លោកស្រី **ថៅ សេដ្ឋចាន់លីដា** | អនុប្រធាននាយកដ្ឋាននៃនិយ័តករគណនេយ្យនិងសវនកម្ម | អនុប្រធាន |
| - លោក **រិន រដ្ឋា** | អនុប្រធាននាយកដ្ឋាននៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| - លោក **ណាង សេរីវុធ** | អនុប្រធាននាយកដ្ឋាននៃនិយ័តករបរធនបាលកិច្ច | សមាជិក |
| - លោក **ព្រំ សេរីឧត្តម** | អនុប្រធាននាយកដ្ឋាន នៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | សមាជិក |
| - លោក **ឌីវ ម៉ារ៉ាដែន** | អនុប្រធាននាយកដ្ឋាន នៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ | សមាជិក |
| - លោក **ឈុន ចាន់ណា** | ប្រធានការិយាល័យនៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. | សមាជិក |
| - លោក **ចេស ចាន់ដេត** | ប្រធានការិយាល័យនៃនិយ័តករបរធនបាលកិច្ច | សមាជិក |

- លោក **ជីវ ម៉ា** ប្រធានការិយាល័យនៃនិយ័តករគណនេយ្យនិងសវនកម្ម សមាជិក
- លោក **ចេង ជុងចេង** អនុប្រធានការិយាល័យនៃនិយ័តករធានារ៉ាប់រងកម្ពុជា សមាជិក
- លោក **ស៊ុន ហេង** អនុប្រធានការិយាល័យនៃនិយ័តករមូលបត្រកម្ពុជា សមាជិក
- លោក **ចំរើន សិរីបុត្រ** អនុប្រធានការិយាល័យនៃនិយ័តករមូលបត្រកម្ពុជា សមាជិក
- លោក **ជ រ័ត្តនា** អនុប្រធានការិយាល័យនៃនិយ័តករគណនេយ្យនិងសវនកម្ម សមាជិក
- លោក **អ៊ុង គីមហួរ** អនុប្រធានការិយាល័យ នៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ សមាជិក
- លោកស្រី **ឈុន សុគា** មន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. សមាជិក
- លោក **ខេន ចន្ថា** មន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. សមាជិក
- លោក **សុខ ពិសិដ្ឋ** មន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. សមាជិក
- លោកស្រី **វណ្ណ សោភ័ណ្ឌ** មន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. សមាជិក
- លោក **ខែម ពុទ្ធា** មន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. សមាជិក
- លោក **ឈឿង ពិនថង** មន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. សមាជិក
- លោក **រិន វណ្ណាត** មន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. សមាជិក
- លោក **ឃួយ សុជាតិ** មន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. សមាជិក
- លោក **នេព វណ្ណាសុភក្រ្តឧត្តម** មន្ត្រីនៃនិយ័តករធានារ៉ាប់រងកម្ពុជា សមាជិក
- លោក **ឡៃ ចាន់ណារ៉ា** មន្ត្រីនៃនិយ័តករធានារ៉ាប់រងកម្ពុជា សមាជិក
- លោក **សុខ ឆាយា** មន្ត្រីនៃនិយ័តករសន្តិសុខសង្គម សមាជិក។

**ប្រការ៤.-**

ក្រុមការងារបច្ចេកទេសជាសេនាធិការឱ្យក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ មានតួនាទីនិងភារកិច្ចដូចខាងក្រោម÷

- បំពេញមុខងារជាសេនាធិការបច្ចេកទេសជូនក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- រៀបចំកិច្ចប្រជុំនិង/ឬសិក្ខាសាលា លទ្ធផលឬកំណត់ហេតុនៃកិច្ចប្រជុំ និង/ឬសិក្ខាសាលា ដែលមានគោលបំណងពិគ្រោះយោបល់និងប្រមូលធាតុចូលបន្ថែម សំដៅធានាឱ្យការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារកាន់តែមានលក្ខណៈពេញលេញនិងគ្រប់ជ្រុងជ្រោយ

- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពការងារនិងធាតុចូលជូនក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារ។

**ប្រការ៥.-**

ក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងក្រុមការងារបច្ចេកទេសជាសេនាធិការ ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារនីមួយៗ។ ក្នុងករណីប្រធានក្រុមការងារនីមួយៗអវត្តមានឬមានករណីចាំបាច់ ប្រធានក្រុមការងារនីមួយៗអាចផ្ទេរសិទ្ធិជូនអនុប្រធានក្រុមការងារដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិកក្រុមការងារនីមួយៗ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានឬអនុប្រធានក្រុមការងារក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់។

**ប្រការ៦.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ. និងប្រធានអង្គភាពក្រោមឱវាទ អ.ស.ហ. ដែលពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១និងប្រការ៣ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ន៧/

ថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:-**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ